# ការយល់ដឹងអំពីមមាចត្នោត និងវិធានការណ៍ការពារ





សត្វមមាចត្នោតកំពុងបំផ្លាញស្រូវ  ពងរបស់សត្វមមាចត្នោត (រូបភាពអុីរី)

## ១.លក្ខណ:សំគាល់ និងវដ្តជីវិត

មមាចត្នោតមានពណ៌ស្រដៀងនឹងដី ឬពណ៌ត្នោត ហើយវាអាចពងបានពី ២០០ ទៅ ៧០០ ពង នៅលើស្លឹកស្រូវ និងស្រទបស្លឹកស្រូវដែលមានគំរបសន្ទះធំដូចស្និតចេក។ កូនវាញាស់ចេញពីពងក្នុងរយ:ពេលពី ៧ ទៅ ៩ ថ្ងៃ ដោយញាស់ក្នុងដំណាក់កាលដំបូងមានពណ៌ស និងដំណាក់កាលបន្ទាប់ទៀតមានពណ៌ត្នោត ។

**វដ្តជីវិតរបស់មមាចត្នោត (រូបភាពពី IRRI)**




## ២.រោគសញ្ញាបំផ្លាញ

- ដំណាំបានប្រែពណ៌លឿងដូចជា ក្រាភ្លើង ឬ ដូចគេដុត
- ដំណាំដែលទទួលរងនូវការបំផ្លាញមានសភាពស្ងួតរហូតដល់ងាប់តែម្តង
- នៅពេលដែលយើងដើរក្នុងស្រែមានពួកសត្វល្អិតច្រើនហើរឡើង ។

## ៣.លក្ខណ:បំផ្លាញ

សត្វមមាចត្នោតវាចូលចិត្តរស់នៅលើដើមស្រូវនៅជាប់ប៉ប្រកនឹងមាត់ទឹក ។ វាបឺតជញ្ជក់រុក្ខរសរបស់ដំណាំនៅតាមដើមស្រូវ ។ នៅពេលដំណាំទទួលការបំផ្លាញដំបូងស្លឹកស្រូវឡើងពណ៌លឿង និងបន្ទាប់មកស្លឹកស្រូវប្រែពណ៌ទៅជាប្រផេះ និងមានសណ្ឋានដូចខ្លោចឆេះនៅកន្លែងដែលទទួលរងនូវការបំផ្លាញធ្ងន់ធ្ងរ ។ មមាចត្នោតជាភ្នាក់ងារចម្លងជំងឺវីរុសដូចជា ជំងឺគៀស្មៅ ជំងឺគៀមូលស្លឹក និងជំងឺគៀស្រពោនស្លឹក ។ នៅពេលដែលដំណាំស្រូវនៅខ្ចី និងមានអាហារសំរាប់ចិញ្ចឹមជីវិតពួកមមាចត្នោតមានសណ្ឋានស្លាបខ្លី ប៉ុន្តែវានឹងប្រែប្រួលសណ្ឋានទៅជាស្លាបវែងនៅពេលដែលដំណាំចាស់ និងជិតអស់ចំណីដើម្បីធ្វើការបំលាស់ទី ។ ចំនួនមមាចត្នោតចាប់ពី ១៥ ក្បាល ក្នុងមួយគុម្ព គេបានចាត់ទុកថាវាមានលក្ខណ:បំផ្លាញធ្ងន់ធ្ងរ និងត្រូវមានវិធានការណ៍ទប់ស្កាត់ជាបន្ទាន់ ។






**ការបំផ្លាញរបស់សត្វមមាចត្នោតនៅស្ទឹងជីនិត**　　**មមាចត្នោត និងសត្រូវធម្មជាតិរបស់វា (ស្រីងគោក)**

**ចំណាំៈ** នៅពេលមេឃមានសភាពអួរអាប់ ស្ទូងចន្លោះគុម្ពតូច ឬ ញឹកពេក និងមានការប្រើប្រាស់ជីអាសូតច្រើនពេក (ជីអ៊ុយរ៉េ ឬ ជីស) វាជួយទាក់ទាញ និងបង្កើនទូវការបំផ្លាញរបស់សត្វមមាចត្នោតថែមទៀត ។

**៤.វិធានការណ៍ការពារ និងទប់ស្កាត់ចាំបាច់មួយចំនួន**

- កុំប្រើប្រាស់ជីអាសូត (ជីអ៊ុយរ៉េ ឬ ជីស) ហួសកំរិត និងត្រូវប្រើប្រាស់អោយបានសមស្រប និងមានការពិភាគ ដិតដល់មុនសំរេចចិត្ត
- ការតំកល់ទឹកទុកនៅក្នុងស្រែគួរជៀសវាង ឬ ត្រូវបង្ហូរទឹកចេញអោយអស់ពីស្រែ បើសិនជាយើងពុំមានលទ្ធភាព ពន្លិចស្រែ ។ ក្នុងករណីអាចពន្លិចស្រែបានត្រូវពន្លិចស្រែនៅក្នុងរយៈពេល ១ ថ្ងៃ (២៤ ម៉ោង) ហើយធ្វើការ បង្ហូរទឹកចេញវិញ និងប្រមូលពួកសត្វមមាចដែលហូរតាមទឹកអោយអស់ក្នុងពេលនោះដងដែរ
- ការប្រើប្រាស់អន្ទាក់ភ្លើងនៅក្នុងភូមិ ដើម្បីធ្វើការព្យាករណ៍ប្រជាករ ឬ វត្តមានពួកមមាច
- នៅក្នុងស្រែ និងតាមភ្លឺស្រែត្រូវតែសំអាតស្មៅ ព្រោះវាអាចជាជម្រករបស់សត្វមមាច
- ពួកមមាចត្នោត យើងអាចគ្រប់គ្រងវាតាមរយៈបង្កអោយពន្លឺថ្ងៃចាំងចូលដល់ផ្នែកខាងក្រោមនៃដំណាំ ឬ ដើមស្រូវ
- ប្រើស្បៃមុង និងកន្ត្រងបក់សត្វល្អិត ដើម្បីប្រមូលសត្វល្អិតចេញពីស្រែហើយត្រូវតែធ្វើអោយបានច្រើនគ្នា និង បានច្រើនកន្លែងក្នុងពេលជាមួយគ្នា
- ចន្លោះគុម្ពរាងទូលាយ ក៏ជាកត្តាមួយជួយការពារការកកើតសត្វល្អិត (កុំស្ទូងញឹកពេក)
- អាចប្រើប្រាស់ប្រេងម៉ាសូត ១ លីត្រ ក្នុង ១ ហិកតា លាយជាមួយដីខ្សាច់ ២៥ គីឡូក្រាម ១ ហិកតា បាចនៅ ក្នុងស្រែដែលមានការបំផ្លាញពីពួកមមាចត្នោត ប៉ុន្តែត្រូវតែមានការប្រុងប្រយ័ត្ន ពីព្រោះវាអាចធ្វើអោយប៉ះពាល់ ដល់បរិស្ថាន ។


**ប្រភពៈ លឹម សុគន្ធដារុណា (២០០៨) សត្វល្អិតបំផ្លាញដំណាំស្រូវសំខាន់ៗ បោះពុម្ពផ្សាយដោយអង្គការ សេដាក**